អង្គរបុរី

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ សាសនាទាំងអស់នៅប្រទេសកម្ពុជា ពុំដែលមានទំនាស់នឹងគ្នាឡើយ ។

www.hoksavann.org

ថ្ងៃទី១ ឧសភា ២០១៣



គេសង្កេតឃើញនៅប្រទេសកម្ពុជា ជាច្រើនសតវត្សរ៍មកហើយ ខ្មែរមានកាន់សាសនាជាច្រើន ជាពិសេសជំនាន់ដើម មនុស្សលោកស្ទើរតែគ្រប់ប្រទេសកាន់លទ្ធិព្រលឹងនិយម ដោយយល់ថា វត្ថុធម្មជាតិទាំងអស់មានព្រលឹងវិញ្ញាណ ក្រោយមកមានការវិវត្តន៍យល់ថា វត្ថុធម្មជាតិទាំងនោះគ្មានចិត្តវិញ្ញាណទេ តែមានទេវៈមួយរូបនៅថែរក្សាធម្មជាតិទាំងនោះ ។ ក្រោយមកទៀត មានគំនិតខ្ពស់ជាងនេះ គឺយល់ថាមានព្រះជាម្ចាស់បង្កើតលោក ទើបបង្កើតបានជាសាសនាព្រាហ្មណ៍ ដែលសព្វថ្ងៃហៅថា សាសនាហិណ្ឌូ សាសនាគ្រិស្ត សាសនាមូស្លីម ដែលជាសាសនាដ៏ធំក្នុងលោក ។ ព្រះពុទ្ធសាសនាក៏ជាសាសនាដ៏ធំមួយដែរ បានកើតឡើងក្នុងលោក ។ ចំនួនមនុស្សដែលកាន់សាសនាធំៗទាំងបួននេះពុំទាន់មានក្រុមណាធ្វើស្ថិតិឲ្យបានពិតប្រាកដ អំពីចំនួនមនុស្សអ្នកកាន់សាសនានីមួយៗ ប៉ុន្តែគេដឹងថា សាសនាព្រះយេស៊ូមានចំនួនមនុស្សកាន់ច្រើនជាងគេ ។

តាមប្រវត្តិសាស្ត្រកម្ពុជា មានកាន់សាសនាព្រាហ្មណ៍ផង កាន់ព្រះពុទ្ធសាសនាផង ។ ក្រោយមកទៀត ក្រោយសម័យមហានគរ ខ្មែរកាន់ព្រះពុទ្ធសាសនាថេរវាទ ឈប់កាន់សាសនាព្រាហ្មណ៍ ។ មានសាសនាដ៏ធំពីរទៀតបានកើតឡើងនៅប្រទេសកម្ពុជា គឺសាសនាព្រះយេស៊ូនិងសាសនាឥស្លាម ។ មតិជាតិនិងមតិអន្តរជាតិបានកត់សម្គាល់ដោយចិត្តកោតសរសើរផងថា ប្រទេសកម្ពុជាមានសាសនាច្រើន ប៉ុន្តែសាសនាទាំងនោះរស់នៅជាមួយគ្នាដោយសុខក្សេមក្សាន្ត ពុំដែលមានទំនាស់គ្នាឡើយ បើមានទំនាស់គ្នាបន្តិចបន្តួច ក៏ពុំប្រើហិង្សារហូតបង្ហូរឈាមគ្នាឡើយ ដែលផ្ទុយគ្នាពីប្រទេសខ្លះ មានបញ្ហាទំនាស់សាសនារហូតបង្ហូរឈាមគ្នា ។ ខ្មែរកាន់សាសនាណាក៏ដោយ ទឹកចិត្តនៅតែរាប់អានស្រឡាញ់គ្នាដូចធម្មតា។

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាគ្រប់ជំនាន់ វៀរលែងតែរដ្ឋធម្មនុញ្ញខ្មែរក្រហម ទោះបីចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋក៏ដោយ ក៏សាសនាដទៃទៀតមានសិទ្ធិបំពេញសកម្មភាពតាមសាសនារបស់ខ្លួន នេះជាច្បាប់ដ៏ល្អថ្លៃថ្លាណាស់របស់ប្រទេសកម្ពុជា ដែលបើកឲ្យប្រជាពលរដ្ឋគោរពសាសនាតាមជំនឿរបស់ខ្លួន ។ ប្រទេសដែលកាន់របបប្រជាធិបតេយ្យសេរី តែងតែគោរពឆន្ទៈរបស់ប្រជាពលរដ្ឋ ព្រោះអំណាចរបស់ខ្លួនកើតចេញមកពីប្រជាពលរដ្ឋ គឺប្រជាពលរដ្ឋជាម្ចាស់អំណាច ។ មិនថាតែប្រទេសកាន់របបប្រជាធិបតេយ្យទេ សូម្បីប្រទេសកាន់របបកុម្មុយនិស្ត បានបើកឲ្យមានការគោរពសាសនា តាមជំនឿរបស់ប្រជាពលរដ្ឋ ដូចប្រទេសចិនកុម្មុយនិស្ត ដែលពីមុនលោកម៉ៅ-សេទុងបានធ្វើបដិវត្តន៍វប្បធម៌បំបាត់ជំនឿផ្សេងៗរបស់ប្រជាពលរដ្ឋ ។

កាលកំណាកំណើតកើតមានឡើងនៃមនុស្សលោក មនុស្សបានលើកយកឧត្តមគតិសាសនាធ្វើជាច្បាប់សំរាប់គ្រប់គ្រងប្រទេសរៀងខ្លួន ។ លុះចំណេរក្រោយមក មនុស្សមានចំណេះឆ្លងតាមការពិសោធន៍របស់ខ្លួន បានយកខ្លឹមសារសាសនាមកផ្សំនឹងចំណេះដឹងរបស់ខ្លួន មកផ្សំធ្វើជាច្បាប់សំរាប់គ្រប់គ្រងប្រទេស ។ ក្នុងន័យនេះ របបប្រជាធិបតេយ្យបានចាប់កំណើតតាំងពីបុរាណកាលនៅប្រទេសក្រិក ។ ប្រជាពលរដ្ឋនៃក្រុងអាថែននៃប្រទេសក្រិក បានផ្លាស់ប្តូរវេនគ្នាគ្រប់គ្រងភូមិស្រុករបស់ខ្លួន ។ លុះពេលក្រោយមក ប្រជាពលរដ្ឋកាន់តែមានចំនួនច្រើនឡើង ទើបគេចាត់តំណាងឲ្យធ្វើការជំនួសវិញ ហៅថាតំណាងប្រជាពលរដ្ឋ ដោយជ្រើសរើសអ្នកមានសមត្ថភាពម្នាក់ឲ្យដឹកនាំសង្គម ហៅថាប្រធានាធិបតី ។ លុះសម័យក្រោយមក គេសិក្សាយកគោលគំនិតនេះខ្លះ មកច្នៃរចនាលទ្ធិប្រជាធិបតេយ្យឲ្យល្អប្រណីតឡើង តាមការយល់ឃើញរបស់ខ្លួន ។ របបគ្រប់គ្រងនេះសុទ្ធតែដកស្រង់ចេញមកអំពីទស្សនវិជ្ជាសាសនា ។

ចំពោះព្រះពុទ្ធសាសនា ព្រះអង្គរកឃើញថា សេចក្តីសុខក្នុងសង្គមមនុស្ស កើតពីការមិនបៀតបៀនគ្នា ។ ការមិនបៀតបៀនគ្នា ដែលបាលីថា អហិង្សា ដែលជាហេតុធ្វើឲ្យសង្គមតូចសង្គមធំ រហូតសហគមន៍អន្តរជាតិបានសុខសន្តិភាព ។ មិនបៀតបៀនដោយកាយ គឺមិនសម្លាប់ មិនលួច មិនប្រព្រឹត្តខុសក្នុងកាម ។ មិនបៀតបៀនដោយវាចា គឺមិននិយាយកុហក ពោលពាក្យពុំពិត មិននិយាយពាក្យញុះញង់បំបែកបំបាក់ មិននិយាយពាក្យតិះដៀលប្រមាថមើលងាយ មិននិយាយពាក្យឥតប្រយោជន៍ ។ មិនត្រឹមតែវៀរចាកកាយទុច្ចរិត វចីទុច្ចរិតប៉ុណ្ណោះទេ សូម្បីចិត្តក៏មិនត្រូវគិតចង់បានទ្រព្យសម្បត្តិអ្នកដទៃ ចង់ព្យាបាទអ្នកដទៃ និងមិនត្រូវមានគំនិតយល់ខុសឡើយ នេះជាកុសលកម្មបថ១០ ។ មិនត្រឹមតែព្រះពុទ្ធសាសនាទេ ដែលបង្រៀនមនុស្សកុំឲ្យបៀតបៀនគ្នា ឲ្យស្រឡាញ់រាប់អានគ្នា មិនប្រកាន់ជាតិសាសន៍សាសនាប៉ុណ្ណោះទេ សាសនាដទៃទៀតក៏ប្រៀនប្រដៅស្រដៀងគ្នានេះដែរ ដូចសាសនាព្រះយេស៊ូប្រៀនប្រដៅសាវករបស់ព្រះអង្គថា ចូរអ្នកស្រឡាញ់អ្នកជិតខាងអ្នក ឲ្យដូចស្រឡាញ់ខ្លួនអ្នកដែរ ។ រហូតព្រះអង្គពោលថា បើគេទះកំភ្លៀងអ្នកម្ខាង ចូរអ្នកបែរឲ្យគេទះម្ខាងទៀតចុះ ។ ពាក្យនេះបានសេចក្តីថា ព្រះអង្គមិនឲ្យបៀតបៀនអ្នកដទៃ ដែលបៀតបៀនព្រះអង្គឡើយ ។ ស្រដៀងគ្នានឹងព្រះពុទ្ធសាសនា ឲ្យផ្សាយមេត្តាករុណាក្នុងព្រហ្មវិហារ ឲ្យស្រឡាញ់សត្រូវរបស់ខ្លួន ឲ្យស្មើនឹងស្រឡាញ់ខ្លួនអ្នកដែរ ។

ពុទ្ធភាសិតនៅក្នុងគម្ពីរធម្មបទពោលថា ជំនះណាដែលត្រឡប់ចាញ់វិញ ជំនះនោះពុំប្រសើរឡើយ ជំនះណាដែលមិនត្រឡប់ចាញ់វិញ ទើបជាជំនះប្រសើរ ។ ជំនះដែលត្រឡប់ចាញ់វិញ ដូចជំនះដោយលេងល្បែងផ្សេងៗ ជំនះដោយឈ្លោះប្រ-

*កែកគ្នារហូតប្រើហិង្សាជាដើម ។ ឯជំនះដែលមិនត្រឡប់ចាញ់វិញ គឺឈ្នះខ្លួនឯង មិនមានលោភៈ ទោសៈ មោហៈ មិនបៀតបៀនអ្នកដទៃដោយមធ្យោបាយណាមួយ ។*

*ត្រឡប់មកប្រធានបទវិញ សាសនាទាំងអស់នៅប្រទេសកម្ពុជា ពុំដែលមានទំនាស់គ្នា រស់នៅជាមួយគ្នាប្រកបដោយសេចក្ដីសុខសាន្ត គោរពសិទ្ធិគ្នាទៅវិញទៅមក ក្រោមម្លប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។ យើងសូមបួងសួង សូមសាសនាទាំងអស់នៅប្រទេសកម្ពុជា រស់នៅជាមួយគ្នា ប្រកបដោយសេចក្ដីសុខក្សេមក្សាន្តតរៀងទៅ ហើយសូមឲ្យចំរើនលូតលាស់តាមសាសនារៀងៗខ្លួន ។៚*

*　　　　*

*